# ប្រាសាទចិនស្រម ឬជាន់ស្រាំ ឬប្រាសាទព្រៃវែង

ប្រាសាទចិនស្រម ស្ថិតនៅដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិព្រៃវែង ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ មានចំនុចនិយាមការ X-451163 Y-1539763។ យើងអាចធ្វើដំណើរតាមទីរួមស្រុកគូលែនកាត់តាមភូមិញ្ញូរជ្រូក ឆ្ពោះទៅកាន់ភូមិព្រៃវែងចម្ងាយប្រមាណ ២៣គីឡូម៉ែត្រ។ ម្យ៉ាងទៀតយើងអាចធ្វើដំណើរតាមប្រាសាទកោះកេរ ទៅទិសខាងជើង ឆ្លងកាត់ស្ទឹងសែន និងឆ្លងកាត់ភូមិសម្បូរ ឆ្ពោះទៅកាន់ភូមិព្រៃវែងប្រមាណ១៨គីឡូម៉ែត្រ ដោយផ្លូវទៅកាន់តំបន់នោះមានការលំបាកខ្លាំងនៅរដូវវស្សា។

ប្រាសាទចិនស្រម អ្នកស្រុកក្នុងតំបន់ច្រើនហៅថា ប្រាសាទព្រៃវែង ឬប្រាសាទជាន់ស្រាំ (រូបលេខ១)។ ប្រាសាទនេះកសាងអំពីឥដ្ឋ មានតួ៥បែរទៅទិសខាងកើត សង់លើឃឿនថ្មបាយក្រៀមមាន៣ថ្នាក់ នៅជុំវិញបរិវេណប្រាសាទមានហោត្រៃចំនួន២សាងអំពីឥដ្ឋ មានសំណង់ជាបន្ទប់រាងចតុកោណកែងចំនួន៨សាងអំពីថ្មភក់ និងថ្មបាយក្រៀម មានគោបុរៈចំនួន២នៅទិសខាងកើត និងខាងលិចនៃប្រាសាទ មានកំផែងថ្មបាយក្រៀមព័ទ្ធជុំវិញ មានស្រះទឹក និងបារាយណ៍នៅទិសខាងកើត។ ផ្អែកតាមរចនាសម្ព័ន្ធរបស់ប្រាសាទ និងភស្តុតាងជាច្រើនដែលលនៅសល់ក្នុងតំបន់នេះ យើងអាចដឹងថាប្រាសាទនេះសាងនៅសតវត្សទី១០ នៃគ.ស និងបានជួសជុលកែលំអឡើងវិញនៅសតវត្សទី១១ នៃគ.ស ដើម្បីឧទ្ទិសចំពោះព្រហ្មញ្ញសាសនា។

តួប៉មកណ្តាលសាងអំពីឥដ្ឋ លើឃឿនជាន់ទី៣ ឃឿននេះរៀបជាថ្មភក់ មានឆ្លាក់ក្បាច់លម្អច្រើន និងមានលក្ខណៈផ្ចិតផ្ចង់។ តួប៉មនេះ កសាងឡើងវិញនៅស.វទី១១ កំឡុងឆ្នាំ១០១៨ នៃគ.ស និងមានសិលាចារឹកលើមេទ្វារខាងជើងនៃតួប៉មកណ្តាល K.1360 ចារជាភាសាខ្មែរចំនួន៧បន្ទាត់ ដែលមានសភាពរលុបពិបាកក្នុងការអាន តាមរយៈកាលបរិច្ឆេទខាងលើយើងអាចដឹងថា ប្រាសាទនេះស្ថិតនៅក្នុងរាជព្រះបាទសូរ្យវរ្ម័នទី១ ការស្មិដ្ឋាននេះគឺយោងតាមសិលាចារិកដែលចារនៅលើមេទ្វារនេះ(រូបលេខ២)។ បើតាមសិលាចារឹកមួយដែលចារលើមេទ្វារមួយ នៃប្រាសាទភ្នំសណ្តកក៏បាននិយាយអំពីរាជ្យគ្រូរបស់ព្រះបាទ

អត្ថបទដោយ៖ លោក លឹម វណ្ណច័ន្ទ

សូរ្យវរ្ម័នទី១ ដែលព្រះអង្គបានបញ្ជាឱ្យមកជួសជុលប្រាសាទ និងចារសិលាចារឹកនៅទីនោះផងដែរ។ ក្នុំសណ្តុកមានចំងាយប្រមាណ៦គីឡូម៉ែត្រពីប្រាសាទចិនស្រមនេះ។ នៅជុំវិញតួប៉មកណ្តាលមានតួប៉មតូចៗចំនួន៤សង់នៅលើជ្រុងឃឿនទីមួយៗនៃជាន់ទី២ ដោយសង់អំពីឥដ្ឋបែរមុខទៅកើតមានសភាពបាក់បែក។ ប្រាសាទតូចៗទាំងនេះ បើពិនិត្យលើរចនាសម្ព័ន្ធ និងក្បាច់លម្អនៅលើផ្តែរប្រាសាទ គឺទំនងសាងនៅស.វទី១០នៃគ.ស ក្នុងរចនាបថកោះកេរ។ ឃឿនជាន់ទី១ និងទី២ សាងអំពីថ្មបាយក្រៀម។ ផ្នែកខាងក្រោមនៃទិសខាងកើតមានហោត្រៃចំនួន២ សាងអំពីឥដ្ឋបែរមុខមកទិសខាងលិច បានបាក់រលំស្ទើរទាំងស្រុង។ ក្នុងនោះឃើញមានសំណង់រាងចតុកោណកែងមានលក្ខណៈដូចជា បន្ទប់សម្រាប់ស្នាក់នៅ ឬជាឃ្លាំង និងមានរន្ធសម្រាប់ខ្យល់ចេញចូល បច្ចុប្បន្នសំណង់នេះបានបាក់រលំស្ទើរទាំងស្រុង ដោយបន្សល់គំនរថ្មបាយក្រៀមជាជញ្ជាំង និងសសរធ្វើពីថ្មភក់(រូបទី៣-៤)។ គោបុរៈខាងកើត និងខាងលិចកសាងឡើងវិញថ្មភក់ស.វទី១១ ដំណាលគ្នានឹងតួកណ្តាល ដោយមានយកផ្តែរស.វទី១០គ.សមកប្រើប្រាស់ឡើងវិញ(រូបទី៥-៦-៧) មានកំផែងថ្មបាយក្រៀមព័ទ្ធជុំវិញ(រូបទី៨)។ ផ្តែរខាងកើតនៃគោបុរៈកើត ជាផ្តែរដែលស្ថិតក្នុងរចនាបទឃ្លាំង ដែលអាចកសាងក្នុងរាជព្រះបាទសូរ្យវរ្ម័នទី១(រូបទី៧) ចំណែកខាងលិចនៃគោបុរៈខាងកើត (រីបលេខ៦) ជាផ្តែរដែលមានលក្ខណៈប្រហាក់ប្រហែលនឹងរចនាបទកោះកេរ ដែលសាងក្នុងស.វទី១០គ.ស នេះមានន័យថាផ្តែរនេះអាចនឹងត្រូវបានប្រើប្រាស់ឡើងវិញ។ នៅភាគខាងកើត នៃគោបុរៈខាងកើត មានស្រះទឹកចំនួន២ និងស្រះទឹកចំនួន២ទៀតនៅភាគខាងលិច នៃគោបុរៈខាងលិច ស្រះទឹកទាំង៤នេះ ជញ្ជាំងសង់ពីថ្មបាយក្រៀមព័ទ្ធជុំវិញកំពស់ប្រមាណ២ម៉ែត្រ ដែលកម្រជួបប្រទះ (រូបទី៩)។ ប្រមាណ១០០ម៉ែត្រខាងកើតគោបុរៈខាងកើត មានគ្រឹះថ្មបាយក្រៀមរៀងកាកបាទយើងពុំឃើញមានសំណង់ថ្មនៅខាងលើនោះទេ។ ប្រមាណ៤០០ម៉ែត្រនៅខាងកើតប្រាសាទមានបារាយណ៍មួយដែលមានបណ្តោយប្រមាណ១២០០ម៉ែត្រ និងទទឹងប្រមាណ៧០០ម៉ែត្រ ដែលលាតសន្ធឹងពីជើងទៅត្បូង ដែលអ្នកស្រុកហៅថាទំនប់ក្រោម បារាយណ៍នេះមានរៀបថ្មបាយ ក្រៀមព័ទ្ធជុំវិញ។ នៅខាងលិចប្រាសាទប្រមាណ៤០០ម៉ែត្រ ក៏មានស្នាកស្នាមទំនប់មួយទៀត

អត្ថបទដោយៈ លោក លឹម វណ្ណច័ន្ទ

ដែលអ្នកស្រុកហៅថាទំនប់លើ មានបណ្តោយប្រមាណ៦០០ម៉ែត្រ និងទទឹង៣០០ម៉ែត្រ។ នៅផ្នែកខាងជើងនៃប្រាសាទ មានស្នាកស្នាមផ្លូវប្រមាណ២០០០ម៉ែត្រដែលនៅខាងជើងឈៀងខាងលិច(រូបទី១០)។

តាមការពិនិត្យតំបន់នេះជាទីតាំងសំខាន់មួយក្នុងសម័យកោះកែរ(លិង្គបុរៈ) តើប្រាសាទចិនស្រមអាចជាប្រាសាទសម្រាប់រាជ្យ? រាជ្យធានីកោះកែរមានមានព្រះមហាក្សត្រ២អង្គគ្រងរាជគឺព្រះបាទជ័យវរ្ម័នទី៤ (៩២៨-៩៤១គ.ស) និងបុត្រព្រះអង្គព្រះនាមហស៌វរ្ម័នទី២(៩៤២-៩៤៤គ.ស) សោយរាជ្យបាន៣ឆ្នាំក៏សោយទីវង្គត់ មានមរណៈនាមថា **ព្រហ្មលោក**[១]។ ក្រោយមកដល់រាជ្យព្រះបាទរាជេន្ទ្រវរ្ម័នទី២ (ឆ្នាំ៩៤៤-៩៦៨គ.ស) បានយាងត្រលប់ទៅ យសោធរបុរៈវិញ (ក្រុងអង្គរ) ដែលបានសាងប្រាសាទប្រែរូប។ ប្រាសាទកោះកែរ មានចម្ងាយ៦គ.ម និងប្រាសាទចិនស្រមមានចម្ងាយ៧គ.ម ស្ថិតនៅសងខាងផ្លូវបុរាណពីអង្គរមកខាងខេត្តព្រះវិហារ។

[១] ត្រឹង ង៉ា ១៩៧៣: ៨៦



រូបលេខ២១



រូបលេខ២២





រូបលេខ២៣-៤







រូបលេខ២៥-៦-៧





រូបលេខ២៨-៩

អត្ថបទដោយ៖ លោក លឹម វណ្ណច័ន្ទ




រូបលេខ១០

## ឯកសារយោង៖

ត្រឹង ងា

១៩៧៣ «ប្រវត្តិសាស្ត្រខ្មែរ» ភាគ១-២, ក្រសួងអប់រំ យុវជន និងកីឡា, ទំព័រ៨៦។